ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស
អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ
លេខ………………………………….

# របាយការណ៍

## បូកសរុបលទ្ធផលការងារប្រចាំខែធ្នូ ឆ្នាំ២០២២

**ក-អំពីកម្លាំង៖**

សរុបរួមចំនួន៖ ០៥នាក់ (ស្រី០២នាក់) អវត្តមាន៖ ០០

**ខ-សកម្មភាព និងលទ្ធផលការងារ**

ខ.១-កិច្ចប្រជុំពង្រឹងកិច្ចសហប្រតិបត្តិការ ការកសាងគោលនយោបាយ និងបទដ្ឋានគតិយុត្តិនានា

<u>សកម្មភាពក្នុងស្រុក</u>

- **ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២២** លោកស្រី វរសេនីយ៍ទោ ថោង សុវត្តិ អនុប្រធានក្រុមជំនួយកិច្ចការ សហប្រតិបត្តិការជាតិ អន្តរជាតិ បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាស្តីពី "**ការលើកកម្ពស់សុវត្ថិភាពស្ត្រី និង កុមារតាមអ៊ីនធឺណិត**" ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជា អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសណ្ឋាគារ Hyatt Regency។ កិច្ចពិភាក្សានេះរៀបចំដោយមាន កិច្ចសហការរវាងក្រុមហ៊ុន Meta និងអង្គការ Auscam Freedom Project និងគាំទ្រដោយ គ.ជ.ប.ជ។ គោលបំណងនៃកិច្ចពិភាក្សា គឺដើម្បីឆ្លុះបញ្ចាំងអំពីកិច្ចខិតខំប្រឹងប្រែងក្នុង ការប្រយុទ្ធប្រឆាំងបទល្មើសជួញដូរមនុស្ស និងទប់ស្កាត់ភាពរងគ្រោះ ជាពិសេសលើស្ត្រី និងកុមារងាយរងគ្រោះតាមប្រព័ន្ធអ៊ីនធឺណិត។ បន្ទាប់ពីបានស្តាប់មតិស្វាគមន៍របស់លោកបណ្ឌិត ហេង ភក្តី ប្រធានគ្រប់គ្រងគោលនយោបាយសាធារណៈ តំណាងក្រុមហ៊ុន Meta (Facebook) ប្រចាំប្រទេសកម្ពុជា និងប្រទេសឡាវ លោកជំទាវ អនុប្រធាន អចិន្ត្រៃយ៍ គ.ជ.ប.ជ បានមានមតិសំណេះសំណាលបើកកម្មវិធីនៃកិច្ចពិភាក្សា។

- **ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២២** លោកវរសេនីយ៍ត្រី ឆន ដារ៉ារិទ្ធ នាយរងការិយាល័យ ស្រាវជ្រាវព័ត៌មាន និងត្រួតពិនិត្យរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលនៃ ការអនុវត្តផែនការប្រចាំឆ្នាំ ២០២២ - ២០២៣ និងដើម្បីបង្ហាញផែនការស្តីពីកិច្ចការពារកុមារឆ្នាំ ២០២៣ - ២០២៤ ដែលបានរៀបចំដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គាំទ្រដោយអង្គការ យូនីសេហ្វ នៅសណ្ឋាគារកាំបូឌីយ៉ា។ គោលបំណងនៃកិច្ចប្រជុំគឺដើម្បីផ្សព្វផ្សាយពីវឌ្ឍនៈភាពសង្ខេបនៅ កម្រិតលទ្ធផលរយៈពេលវែង ការវាយតម្លៃលទ្ធផលរយៈពេលខ្លី លទ្ធផល និងសមិទ្ធិផលសំខាន់ៗ របាយការណ៍ អនុវត្តគម្រោងរបស់

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ពិគ្រោះយោបល់លើបញ្ហាប្រឈមដើម្បីរកដំណោះស្រាយ និងពិនិត្យសម្រេចផែនការបន្ត។ អញ្ជើញចូលរួមជាគណៈអធិបតីក្នុងកិច្ចប្រជុំមាន **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ លោកជំទាវ ខៀវ បូរី រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា លោកស្រី Marianna Garofalo តំណាងអង្គការយូនីសេហ្វនៅកម្ពុជា ព្រមទាំងឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូ មានវត្តមានសរុបចំនួន ៦១រូប (ស្ត្រី២៣រូប)។

- **ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ និងជាប្រធានក្រុមពិធីការ បដិសណ្ឋារកិច្ច និងសិល្បៈ បានអញ្ជើញដឹកនាំក្រុមការងារតាមការចាត់តាំងរៀបចំ ទិវាជាតិ ១២ធ្នូ ឆ្នាំ២០២២ លើកទី១៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** នាយករដ្ឋមន្ត្រីស្តីទីនៃរាជរដ្ឋាភិបាលកម្ពុជា នៅសាលមហោស្រពកោះពេជ្រ។ គោលបំណងនៃការប្រារព្ធទិវាជាតិ១២ធ្នូ នេះគឺដើម្បីបញ្ជាក់ជូនជនរួមជាតិ និងសហគមន៍ អន្តរជាតិឱ្យបានជ្រាបថា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នៅតែបន្តកិច្ចខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់កាន់តែខ្លាំងក្លា ក្នុងការការពារប្រជាពលរដ្ឋ ប្រទេសជាតិពី ភាពវងគ្រោះទាំងឡាយដោយឧក្រិដ្ឋកម្មជួញដូរមនុស្ស ដែលបានបង្កឱ្យមានវិនាសកម្មជាថ្មីដល់មនុស្សជាតិ ហើយបាន និងកំពុងក្លាយជាទាសភាពសម័យទំនើបគួរឱ្យភ័យខ្លាច និងស្អប់ខ្ពើម។ មិទ្ទិញអបអរសាទរនេះក៏ បង្ហាញនូវស្មារតី សាមគ្គីភាព ជាមួយដៃគូរ ពាក់ព័ន្ធជាតិ និងអន្តរជាតិក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីសុវត្ថិភាព និងការអភិវឌ្ឍន៍ជាតិ។ មិទ្ទិញអបអរសាទរ ១២ធ្នូនេះផងដែរ ក៏ជាការរួមចំណែកដ៏ធំធេង ក្នុងការលើកកម្ពស់ សន្តិសុខសុវត្ថិភាពសង្គម និងសន្តិសុខជាតិឱ្យមានស្ថេរភាព ដើម្បីធ្វើជាមូលដ្ឋានគ្រឹះនៃ ការអភិវឌ្ឍន៍ជាតិគ្រប់វិស័យស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

- **ថ្ងៃទី១៥ - ១៦ ខែធ្នូ ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ អន្តរជាតិ បានអញ្ជើញចូលរួមកិច្ចប្រជុំ ក្រុមការងារខមមីត ថ្នាក់តំបន់ និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីខមមីតលើកទី៥ ក្រោមអធិបតីភាព **លោកជំទាវ ហ៊ូ សាមិត្ត** ប្រធានក្រុមការងារ ខមមីតកម្ពុជា ដែលបានរៀបចំឡើងជាវីដេអូអនឡាញពីចម្ងាយ និងនៅទីស្តីការក្រសួងកិច្ចការនារីផ្ទាល់។ គោលបំណងនៃកិច្ចប្រជុំ គឺផ្តល់ជាវេទិកាមួយ សម្រាប់កិច្ចសន្ទនាជាពហុភាគី ដើម្បីពង្រឹងថែមទៀតនូវ កិច្ចសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្ស រវាងប្រទេសមហាអនុតំបន់មេគង្គ ក៏ដូចជាប្រព័ន្ធប្រកប ដោយប្រសិទ្ធភាព និងនិរន្តភាពដើម្បីកសាង និងដាក់ឱ្យប្រើប្រាស់នូវការផ្តួចផ្តើម ការឆ្លើយតបរួមថ្មី ក្នុងការប្រឆាំងអំពើជួញដូរមនុស្ស។ លោកជំទាវបានអញ្ជើញធ្វើបទបង្ហាញខ្លីទាក់ទងនឹងតួនាទីរបស់រដ្ឋាភិបាល និង កិច្ចសហការរបស់អង្គការដៃគូអភិវឌ្ឍន៍ ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ អញ្ជើញចូលរួមផ្ទាល់ ក្នុងកិច្ចប្រជុំមានសមាជិករបស់ក្រុមការងារខមមីត និងដៃគូពាក់ព័ន្ធសរុបចំនួន ១១រូប (ស្ត្រី០៤រូប)។

- **ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សា កែសម្រួល ខ្លឹមសារ អនុស្សារណៈយោគយល់ រវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងអង្គភាពការពារកុមារ នៃអង្គភាពមូលនិធិកុមារកម្ពុជា ស្តីពីការរួមចំណែកក្នុងសកម្មភាពមនុស្សធម៌ និងយុត្តិធម៌ព្រហ្មទណ្ឌ សម្រាប់អនីតិជននៅព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាព លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ ជាអគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការទាំង៦និង មន្ត្រីពាក់ព័ន្ធ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ តំណាងពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស តំណាងពីនាយកដ្ឋានព្រហ្មទណ្ឌ នាយកដ្ឋានបច្ចេកទេស វិទ្យាសាស្ត្រ នៃអគ្គស្នងការដ្ឋាន នគរបាលជាតិ និងមន្ត្រីពាក់ព័ន្ធ សរុប១៧រូប (ស្រី៣រូប) ។

- **ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញចូលរួមកិច្ចប្រជុំពិនិត្យឡើងវិញ និងឆ្លុះបញ្ចាំងជាមួយដៃគូនៅបំណាច់ឆ្នាំ២០២២ ដែលត្រូវបាន រៀបចំឡើងដោយក្រុមការងារ ASEAN-ACT នៅសណ្ឋាគារភ្នំពេញ។ គោលបំណងនៃកិច្ចប្រជុំគឺដើម្បីផ្តល់ ឱកាសជូនដៃគូពិនិត្យឡើងវិញ និងឆ្លុះបញ្ចាំងអំពីអន្តរាគមន៍កម្មវិធី និងប្រមូលទស្សនៈរបស់ដៃគូអំពី គុណភាព និងវឌ្ឍនភាពនៃកម្មវិធី ក្នុងការសម្រេចបានលទ្ធផលនៃកម្មវិធី និងដើម្បីបង្ហាញ និងចែករំលែកសមិទ្ធផល សំខាន់ៗក្នុងឆ្នាំ២០២២ ក៏ដូចជាបញ្ហាប្រឈមនានាក្នុងការអនុវត្ត ដើម្បីដកស្រង់មេរៀន និងបទពិសោធន៍ ដើម្បីកែលម្អ។ អញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះមាន លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ ជាគណៈអធិបតី អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងតំណាង ស្ថាប័នដៃគូគម្រោងទាំងអស់ និងក្រុមការងារកម្មវិធី ASEAN-ACT។

- **ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២២** លោកស្រី វរសេនីយ៍ទោ ថោង សុវត្ថិ អនុប្រធានក្រុមជំនួយកិច្ចការ សហប្រតិបត្តិការជាតិ អន្តរជាតិ បានអញ្ជើញចូលរួមក្នុងសិក្ខាសាលាស្តីពី “ការប្រមូលធាតុចូលដើម្បីរៀបចំ កម្មវិធីបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស” ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ សិក្ខាសាលានេះបានសហការរៀបចំដោយ គ.ខ.ប.ជ ខេត្តកណ្តាល និងគាំទ្រដោយអង្គការក្តីសង្ឃឹម និងយុត្តិធម៌ (Hope for Justice)។ អញ្ជើញចូលរួមជា គណៈអធិបតីរួមមាន ឯកឧត្តម គង់ សោភ័ណ្ឌ អភិបាលនៃគណៈអភិបាល និងជាប្រធាន គ.ខ.ប.ជ ខេត្តកណ្តាល ឯកឧត្តម ឧត្តមសេនីយ៍ឯក លី តុងហ៊ុយ អគ្គលេខាធិការរង គ.ជ.ប.ជ ឯកឧត្តមអភិបាលរង នៃគណអភិបាលខេត្ត កណ្តាល លោកស្រី Maggie Crewes នាយកប្រចាំប្រទេសនៃអង្គការ Hope for Justice។

- **ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង និងជាប្រធានក្រុមការងារផលិតនិងផ្សព្វផ្សាយវីដេអូអប់រំ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាស្តីពីការបង្កើតវីដេអូបែបខ្លីអប់រំផ្សព្វផ្សាយពាក់ព័ន្ធករណី Cyber Crime ជាមួយលោក រស់ យេង

តំណាងអង្គការ A21 លោក ឃួន សុខពិសិដ្ឋ អនុប្រធាននាយកដ្ឋាន និងលោកនាយការិយាល័យ តំណាងនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា របស់អគ្គស្នងការដ្ឋាននគរបាលជាតិ មានការចូលរួមពីលោក លោកស្រី ជានាយ/នាយរងការិយាល័យ របស់លេខាធិការដ្ឋាន គ.ជ.ប.ជ ជាសមាជិក សមាជិការរបស់ ក្រុមការងារផលិត ផ្សព្វផ្សាយវីដេអូអប់រំ របស់ អគ្គលេខាធិការ គ.ជ.ប.ជ។

- **ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២** លោកវរសេនីយ៍ឯក តាវ វិភក្តិ អនុប្រធានក្រុមជំនួយកិច្ចការ សហប្រតិបត្តិការជាតិ អន្តរជាតិ បានអញ្ជើញចូលរួមកិច្ចប្រជុំពិនិត្យ បូកសរុបរបាយការណ៍ឆ្នាំ២០២២ សម្រាប់បញ្ជូនទៅក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅបន្ទប់ប្រជុំអគ្គលេខាធិការ គ.ជ.ប.ជ។ អញ្ជើញចូលរួមក្នុងកិច្ចប្រជុំមាន ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ប្រធាន អនុប្រធាន និងតំណាងនៃក្រុមជំនួយកិច្ចការទាំង៦ អនុប្រធានលេខាធិការដ្ឋានទទួលបន្ទុកការិយាល័យសរុបផែនការ និងមន្ត្រីពាក់ព័ន្ធនៃក្រុមការងារកំណែរបាយការណ៍។

- **ថ្ងៃទី២៧-២៩ ខែធ្នូ ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង លោកស្រីវរសេនីយ៍ទោ ថោង សុវុត្ថិ អនុប្រធានក្រុមជំនួយកិច្ចការ បានអញ្ជើញអមដំណើរ លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចុះត្រួតពិនិត្យការងារ និងប្រគល់ឧបករណ៍សោតទស្សន៍ (ទូរទស្សន៍ និងឧបករណ៍បំពង សំឡេង) នៅតាមមណ្ឌលទទួលពលករ ច្រកព្រំដែន និងការិយាល័យច្រក ចេញចូលតែមួយ ក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ និងឧត្តរមានជ័យ សម្រាប់ការផ្សព្វផ្សាយលើកកម្ពស់ ការយល់ដឹងរបស់ប្រជាពលរដ្ឋឆ្លងកាត់ព្រំដែនកម្ពុជា-ថៃ អំពីសុខភាពផ្លូវភេទ សិទ្ធិការបន្តពូជ សុខភាពមាតា ទារក/កុមារ ដោយមានកិច្ចសហការគាំទ្រពីអង្គការ UNFPA ជាដៃគូអភិវឌ្ឍន៍ ។

**គ-ទិសដៅបន្ត**

- ត្រួតពិនិត្យ និងបូកសរុបរបាយការណ៍ផ្ញើទៅខាងក្រសួងមហាផ្ទៃ
- រៀបចំប្រព័ន្ធភ្លើងនៅបន្ទប់ប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០២៣

**ប្រធាន**

**ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ**